UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

# ក្លឹបស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌

## FAIR TRIAL RIGHTS ACADEMY (FTRA)

តើលោក-អ្នកជានិស្សិតច្បាប់ ឬនិស្សិតច្បាប់ទើបបញ្ចប់នាពេលថ្មីៗ ចាប់អារម្មណ៍ក្នុងអាជីពជាមេធាវីការពារក្ដី ឬបំពេញការងារតាមបណ្ដាអង្គការនានា ដែលលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌? តើលោក-អ្នកមានបំណងប្រាថ្នាក្នុងការការពារសិទ្ធិមនុស្ស និងមានការប្ដេជ្ញាចិត្តចំពោះយុត្តិធម៌ឬទេ? តើលោក-អ្នកចង់ស្វែងយល់អំពីវិធីនៃការវិវត្តន៍នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលអាចផ្ដល់ផលប៉ះពាល់ស្ដីពីការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ក្នុងវិស័យយុត្តិជាតិឬទេ? ប្រសិនបើចង់ យើងចង់ស្ដាប់នូវមតិ-យោបល់របស់លោក-អ្នក!

<u>គោលបំណង</u>

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR) មានក្ដីសោមនស្ស ដើម្បីជូនដំណឹងអំពីបើកវគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីស្ដីពីមុខវិជ្ជា**សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌-ក្លឹបស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។** វគ្គសិក្សានេះនឹងផ្ដល់ឱកាសដល់សិក្ខាកាមដើម្បីពិចារណាអំពីបញ្ហានៃ**សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌** ទាំងក្នុងបរិបទនៃការជំនុំជម្រះក្ដីនៅតុលាការជាតិ និង អ.វ.ត.ក។ សិក្ខាកាមនឹងមានឱកាសជួបជាមួយមន្ត្រីសំខាន់ៗ ដែលបំពេញការងារនៅ អ.វ.ត.ក និងវិស័យយុត្តិធម៌ជាតិ និងទទួលបានការយល់ដឹងកាន់តែប្រសើរ អំពីសិទ្ធិទទួលបានការជំនុំជម្រះក្ដី ដោយយុត្តិធម៌ ជាមូលដ្ឋានគ្រឹះមួយក្នុងចំណោមមូលដ្ឋានគ្រឹះទាំងឡាយសម្រាប់សិទ្ធិមនុស្សទាំងអស់។

<u>កាលបរិច្ឆេទ</u>

ក្លឹបស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌គឺជាសិក្ខាសាលាមានចំនួន៨ និងមានរយៈពេល២ម៉ោងសម្រាប់សិក្ខាសាលានីមួយៗ។ សិក្ខាសាលាទាំងនេះ នឹងត្រូវចាប់ផ្ដើមពីម៉ោង៤ល្ងាច ដល់ម៉ោង៦ល្ងាច រៀងរាល់ថ្ងៃពុធនៃសប្ដាហ៍នីមួយៗ (លើកលែងតែថ្ងៃឈប់សំរាកផ្លូវការ) ដោយសិក្ខាសាលាលើកទី១នឹងដំណើរការនៅថ្ងៃ<u>**ពុធ ទី០៣ ខែតុលា ឆ្នាំ២០១២**</u>។ ការិយាល័យ OHCHR នឹងចែកជូនវិញ្ញាប័នបត្របញ្ជាក់ការសិក្សាដល់អ្នកចូលរួមទាំងឡាយណា ដែលបានបញ្ចប់ដោយជោគជ័យនៃមុខវិជ្ជាទាំង៨សិក្ខាសាលានេះ។

**ទីកន្លែង**

សិក្ខាសាលាទាំង៦លើកដំបូងនឹងត្រូវរៀបចំឡើងនៅការិយាល័យ OHCHR នាទីក្រុងភ្នំពេញ។ សិក្ខាសាលាលើកទី៧នឹងរៀបចំឡើងនៅអ.វ.ត.ក ដោយផ្តល់ជូនសិក្ខា-កាមនូវមធ្យោបាយធ្វើដំណើរ។ សិក្ខាសាលាលើកទី៨នឹងត្រូវអមដោយពិធីចែកជូនប័នបត្របញ្ជាក់ការសិក្សា និង ពិសារអាហារពេលល្ងាច ដែលនឹងរៀបចំនៅទីកន្លែងណាមួយនាទីក្រុងភ្នំពេញ។

**បេក្ខជនមានសិទ្ធិដាក់ពាក្យ**

ក្លឹបស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌បើកចំហរដល់និស្សិតច្បាប់កម្ពុជា ឬនិស្សិតច្បាប់ទើបបញ្ចប់នាពេលថ្មីៗ។ មុខវិជ្ជានេះនឹងទទួលសិក្ខកាមចំនួន២០នាក់ជាអតិបរមា។ ប្រសិន បើលោក-អ្នកចាប់អារម្មណ៍ក្នុងការចូលរួមក្នុងវគ្គសិក្សាជាន់ខ្ពស់នេះ សូមផ្ញើ*ប្រវត្តិរូបសង្ខេប* និង*លិខិតបញ្ជាក់ការចាប់អារម្មណ៍មួយច្បាប់*តាមរយៈ អ៊ីម៉េលមកលោក ភ័ក្រ្ត សាវ័ន្ត (Pheak Savornt (Mr)) គឺ spheak@ohchr.org ឬលោកស្រី Catherine Phuong: cphuong @ohchr.org។

**កាលបរិច្ឆេទនៃការដាក់ពាក្យ**

ការទទួលពាក្យស្នើសុំរបស់បេក្ខជននឹងត្រូវផុតកំណត់ត្រឹមពាក្យកណ្តាលអាធ្រាត្រ នា**ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២**។ បេក្ខជន ដែលជោគជ័យ ក្នុងការជ្រើសរើសក្នុងវគ្គបណ្តុះបណ្តាលនេះនឹងត្រូវជូនដំណឹងតាមទូរស័ព្ទ និងផ្ញើលិខិតអញ្ជើញចូលរួមក្នុងក្លឹបស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅ**ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១២**នេះ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR) អាស័យដ្ឋាន៖ ផ្ទះលេខ ១០ ផ្លូវ ៣០២ សង្កាត់បឹងកេងកង ១ ភ្នំពេញ
*Cambodia.ohchr.org*, 023 993590